រៀបចំដោយ ៖

AEAS

## សូមអញ្ជើញចូលរួម

# Sousdey AUSTRALIA

## ពិព័រណ៍ព័ត៌មានសាលានៅអូស្ត្រាលីឆ្នាំ ២០២៦

សម្រាប់អាណាព្យាបាល និងសិស្សថ្នាក់ទី ១ - ១០

ស្កេន
ចុះឈ្មោះ
ចូលរួម

ថ្ងៃអាទិត្យ ទី៦ ខែកញ្ញា ឆ្នាំ២០២៦

៩:០០ ព្រឹក - ១:០០ រសៀល

Hyatt Regency Phnom Penh

*បញ្ជាក់៖ ចូលរួមសិក្ខាសាលាដោយសេរីចាប់ពីម៉ោង ៩:០០ ព្រឹក



ELITE COLLEGE OF ENGLISH | NSW GOVERNMENT | Ravenswood | St Aidan's | St Leonard's College | TOORAK COLLEGE | WESLEY COLLEGE

# បញ្ជីឈ្មោះសាលាដែលចូលរួម

| លេខស្តង់ | ឈ្មោះសាលា | រដ្ឋ | ប្រភេទសាលា | សញ្ញាប័ត្រ | ការស្នាក់នៅ |
|---|---|---|---|---|---|
| 1 | Elite College of English | NSW | ការសិក្សារួមថ្នាក់ | ភាសាអង់គ្លេស | អាគារស្នាក់នៅ |
| 2 | NSW Government Schools | NSW | ការសិក្សារួមថ្នាក់ | HSC | អាគារស្នាក់នៅ<br>នៅជាមួយគ្រួសារ |
| 3 | Ravenswood School for Girls | NSW | ស្រី | HSC \| IBDP | ផ្ទះស្នាក់<br>នៅជាមួយគ្រួសារ |
| 4 | St Aidan's Anglican Girls' School | QLD | ស្រី | QCE | អាគារស្នាក់នៅ<br>នៅជាមួយគ្រួសារ |
| 5 | St Leonard's College | VIC | ការសិក្សារួមថ្នាក់ | VCE \| IBDP | នៅជាមួយគ្រួសារ |
| 6 | Toorak College | VIC | ស្រី | VCE | ផ្ទះស្នាក់<br>នៅជាមួយគ្រួសារ |
| 7 | Wesley College | VIC | ការសិក្សារួមថ្នាក់ | VCE \| IBDP | ផ្ទះស្នាក់<br>អាគារស្នាក់នៅ<br>នៅជាមួយគ្រួសារ |







Scan the QR code to go to our website

# ការប្រលងតេស្តAEAS



## តេស្តរបស់ AEAS - ជាលិខិតឆ្លងដែនរបស់អ្នកទៅកាន់សាលាកំពូលនៅប្រទេសអូស្ត្រាលី

សិស្សអាចប្រើរបាយការណ៍តេស្តរបស់ AEAS សម្រាប់ពិនិត្យពាក្យសុំចូលរៀនទៅសាលាជាង ៣០០ នៅប្រទេសអូស្ត្រាលី រួមមានសាលារដ្ឋ និងសាលាឯកជន។

តេស្តរបស់AEAS គឺជាការប្រលងភាសាអង់គ្លេស និងសមត្ថភាពទូទៅដែលគួរឱ្យទុកចិត្តបំផុត និងល្បីល្បាញបំផុតសម្រាប់សិស្សដែលដាក់ពាក្យទៅសាលានៅប្រទេសអូស្ត្រាលី។

មតិយោបល់ផ្តល់ក្នុងរបាយការណ៍លទ្ធផលតេស្ត AEAS គឺត្រឹមត្រូវ និងពឹងផ្អែកលើការប្រមូលទិន្នន័យនិងសង្កេតអស់រយៈពេលជិត ៤០ឆ្នាំ។

## តើអ្វីទៅជាតេស្ត AEAS?

តេស្ត AEAS គឺជាការធ្វើតេស្តលើក្រដាស ដោយផ្ទាល់ និងចំណាយពេលប្រហែល បី ម៉ោង កន្លះ។

តេស្ត AEAS រួមមានជំនាញភាសាអង់គ្លេស (ការអាន ការសរសេរ វាក្យសព្ទ ការស្តាប់ និងការនិយាយ) សមត្ថភាពទូទៅ  និងចំណោទគណិតវិទ្យា។

របាយការណ៍លទ្ធផលតេស្ត AEAS មាន ៣សន្លឹក រួមបញ្ចូលលទ្ធផលតេស្តរបស់សិស្ស របាយការណ៍សាលា ការសង្កេតពីការធ្វើតេស្ត និងព័ត៌មានជាច្រើនផ្សេងទៀត ដើម្បីផ្តល់នូវការណែនាំសម្រាប់សិស្សម្នាក់ៗ។

## ការធ្វើតេស្ត AEAS នៅកម្ពុជា

| កញ្ញា 2026 | តុលា 2026 | វិច្ឆិកា 2026 | ធ្នូ 2026 |
|---|---|---|---|
| 19 | 17 | 21 | 19 |

**Register for an AEAS Test**

# ពិព័រណ៍ព័ត៌មានសាលានៅប្រទេសអូស្ត្រាលី ឆ្នាំ2026

## មានរង្វាន់ពិសេសជូនដល់អ្នកចូលរួមកម្មវិធី



### Elite College of English (NSW)

ផ្តល់ជូនថ្លៃសិក្សាបន្ថែមមួយសប្តាហ៍ដោយឥតគិតថ្លៃ

### NSW Government Schools (NSW)

ផ្តល់ជូនសេវាពាក្យសុំចូលរៀនដោយឥតគិតថ្លៃ (ដែលមានតម្លៃស្មើ  AUD$300)

### Ravenswood School for Girls (NSW)

ផ្តល់ជូនសេវាពាក្យសុំចូលរៀនដោយឥតគិតថ្លៃ ក្នុងរយៈពេល 14 ថ្ងៃ គិតចាប់ពីថ្ងៃពិព័រណ៍

### St Aidan's Anglican Girls' School (QLD)

ផ្តល់ជូនសេវាពាក្យសុំចូលរៀនដោយឥតគិតថ្លៃ និងឯកសណ្ឋានមួយឈុត (រ៉ូបខៀវ និងមួក Panama)

### St Leonard's College (VIC)

ផ្តល់ជូនសេវាពាក្យសុំចូលរៀន ដែលមានតម្លៃ AUD$300 ដោយឥតគិតថ្លៃ

### Toorak College (VIC)

ផ្តល់ជូនសេវាពាក្យសុំចូលរៀនដោយឥតគិតថ្លៃសម្រាប់គ្រួសារដែលបានចូលរួមពិព័រណ៍

### Wesley College (VIC)

ផ្តល់ជូនសេវាពាក្យសុំចូលរៀន និងការបញ្ជាក់ដោយឥតគិតថ្លៃ

# Elite College of English






| ព័ត៌មានអំពីសាលា | |
|---|---|
| ក្រុង/ រដ្ឋ | NSW |
| ឆ្នាំបង្កើត | 2022 |
| ប្រភេទសាលា | ការសិក្សារួមថ្នាក់ |
| ការស្នាក់នៅ | អាគារស្នាក់នៅ |
| កម្មវិធី ELICOS | មាន |
| កម្មវិធីភាសាអង់គ្លេស ផ្សេងទៀត | មាន |
| វិញ្ញាបនបត្របញ្ជាក់ការសិក្សា | PSP/HSP (ភាសាអង់គ្លេស) |
| ចំនួនសិស្សចុះឈ្មោះចូលរៀនសរុប | 135 |
| ចំនួនសិស្សអន្តរជាតិសរុបបច្ចុប្បន្ន (500 ទិដ្ឋាការ) | 85 |
| តម្រូវការតេស្ត AEAS | តម្រូវការ |
| ថ្លៃសិក្សា | AUD $40,000 |
| ថ្លៃកន្លែងស្នាក់នៅ | AUD $450-$550 ក្នុងមួយសប្ដាហ៍ |
| លេខ CRICOS | 04087M |

**Booth Number 1**

វិទ្យាស្ថានភាសាអង់គ្លេស Elite College of English (ECE) គឺជាវិទ្យាស្ថានបង្រៀនភាសាអង់គ្លេសឯកទេសឈានមុខគេនៅទីក្រុងស៊ីដនី ដែលផ្តោតលើការរៀបចំសិស្សអន្តរជាតិឱ្យមានភាពរួចរាល់សម្រាប់ការចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សានៅប្រទេសអូស្ត្រាលី។ ECE គឺជាអ្នកផ្តល់សេវាផ្តាច់មុខនៃវគ្គត្រៀមប្រឡង AEAS ផ្លូវការ និងវគ្គត្រៀមចូលសាលា (School Preparation) នៅរដ្ឋ New South Wales។ យើងក៏ផ្តល់ជូនវគ្គត្រៀម AEAS ផ្លូវការតាមប្រព័ន្ធអនឡាញសម្រាប់សិស្សនៅតំបន់ដែលមិនទាន់មានអ្នកផ្តល់សេវាផ្លូវការក្នុងស្រុក ដូចជា កម្ពុជា វៀតណាម និងថៃ។

កម្មវិធីរបស់យើងរួមមានការអភិវឌ្ឍភាសាអង់គ្លេសសម្រាប់ការសិក្សា ការត្រៀមខ្លួនសម្រាប់ការចូលរៀន កម្មវិធីត្រៀមចូលវិទ្យាល័យ (HSP) កម្មវិធីត្រៀមចូលបឋមសិក្សា (PSP) កម្មវិធីសិក្សាថ្ងៃឈប់សម្រាក (School Holiday Programs) និងកម្មវិធី Study Tour ដែលរៀបចំតាមតម្រូវការ ដើម្បីផ្តល់បទពិសោធន៍សិក្សា និងវប្បធម៌អូស្ត្រាលីយ៉ាងពេញលេញ។ តាមរយៈថ្នាក់រៀនដែលមានសិស្សតិច គ្រូបង្រៀនមានបទពិសោធន៍ ផែនការសិក្សាផ្ទាល់ខ្លួន និងការគាំទ្រផ្នែកសិក្សាយ៉ាងជិតស្និទ្ធ សិស្សនឹងអភិវឌ្ឍជំនាញភាសាអង់គ្លេស ទំនុកចិត្ត និងជំនាញសិក្សាដែលចាំបាច់សម្រាប់ភាពជោគជ័យនៅក្នុងសាលារៀនអូស្ត្រាលី។

ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមគ្រួសារ ភ្នាក់ងារអប់រំ និងសាលាដៃគូ ECE ប្តេជ្ញាបង្កើតផ្លូវអប់រំដ៏រឹងមាំ និងជួយសិស្សឱ្យទទួលបានភាពជោគជ័យផ្នែកសិក្សារយៈពេលវែងនៅប្រទេសអូស្ត្រាលី។

# NSW Government Schools





| ព័ត៌មានអំពីសាលា | |
|---|---|
| ក្រុង/ រដ្ឋ | NSW |
| ឆ្នាំបង្កើត | 1848 |
| ប្រភេទសាលា | ការសិក្សារួមថ្នាក់ |
| ការស្នាក់នៅ | អាគារស្នាក់នៅ<br>នៅជាមួយគ្រួសារ |
| កម្មវិធី ELICOS | មាន |
| កម្មវិធីភាសាអង់គ្លេសផ្សេងទៀត | មាន |
| វិញ្ញាបនបត្របញ្ជាក់ការសិក្សា | HSC |
| ចំនួនសិស្សចុះឈ្មោះចូលរៀនសរុប | ចំនួនប្រែប្រួលតាមសាលា |
| ចំនួនសិស្សអន្តរជាតិសរុបបច្ចុប្បន្ន (500 ទិដ្ឋាការ) | ចំនួនប្រែប្រួលតាមសាលា |
| តម្រូវការតេស្ត AEAS | តម្រូវការ |
| ថ្លៃសិក្សា | AUD $17,000-$20,500 |
| ថ្លៃកន្លែងស្នាក់នៅ | AUD $520 ក្នុងមួយសប្តាហ៍ |
| លេខ CRICOS | 00588M |

**Booth Number 2**

សាលារៀនរដ្ឋ New South Wales (NSW) ផ្តល់ជូននូវឱកាស ការរស់នៅ និងរៀនសូត្រពីក្នុងសហគមន៍ដែលមានវប្បធម៌ចម្រុះ ប្រកបដោយសុវត្ថិភាព និងការទំនាក់ទំនងគ្នាបានយ៉ាងល្អ។

ក្នុងនាមជាបណ្តាញអប់រំធំជាងគេនៅក្នុងប្រទេសអូស្ត្រាលី ប្រព័ន្ធសាលារៀនរបស់យើងត្រូវបានទទួលស្គាល់សម្រាប់កម្រិតគុណភាព លទ្ធផលសិក្សាខ្ពស់ មុខវិជ្ជាសិក្សាច្នៃប្រឌិតសម្បូរបែប និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរួមបញ្ចូលគ្នានៅក្នុងថ្នាក់រៀន។ ការសិក្សានៅសាលារៀនរដ្ឋ NSW គឺសិស្សានុសិស្សអាចសិក្សាបន្តរហូតដល់ថ្នាក់ទី 12 និងជាការត្រៀមខ្លួនដ៏ល្អបំផុតសម្រាប់ការចូលសិក្សានៅសាកលវិទ្យាល័យនានាទាំងក្នុងប្រទេសអូស្ត្រាលី និងអន្តរជាតិ។

# Ravenswood School for Girls





**ព័ត៌មានអំពីសាលា**

| | |
|---|---|
| ក្រុង/ រដ្ឋ | NSW |
| ឆ្នាំបង្កើត | 1901 |
| ប្រភេទសាលា | ស្រី |
| ការស្នាក់នៅ | ផ្ទះស្នាក់<br>នៅជាមួយគ្រួសារ |
| កម្មវិធី ELICOS | គ្មាន |
| កម្មវិធីភាសាអង់គ្លេស ផ្សេងទៀត | មាន |
| វិញ្ញាបនបត្របញ្ជាក់ការសិក្សា | HSC/IBDP |
| ចំនួនសិស្សចុះឈ្មោះ ចូលរៀនសរុប | 1420 |
| ចំនួនសិស្សអន្តរជាតិសរុប បច្ចុប្បន្ន (500 ទិដ្ឋាការ) | 70 |
| តម្រូវការតេស្ត AEAS | តម្រូវការ |
| ថ្លៃសិក្សា | AUD $37,000-$61,000 |
| ថ្លៃកន្លែងស្នាក់នៅ | AUD $38,730 |
| លេខ CRICOS | 02306K |

**Booth Number 3**

សាលារៀន Ravenswood គឺជាសាលាឯកជនសម្រាប់សិស្សស្រី ចាប់ពីថ្នាក់ត្រៀម (Prep) រហូតដល់ថ្នាក់ទី 12 ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ Uniting Church និងមិនមានការប្រឡងជ្រើសរើសសិស្សចូលរៀននោះទេ ហើយសាលាក៏មានជាកន្លែងស្នាក់នៅសម្រាប់សិស្សចាប់ពីថ្នាក់ទី ៧ ឡើងទៅផងដែរ។

សាលារៀន Ravenswood នូវតែបន្តរក្សាប្រពៃណីដ៏រឹងមាំផ្នែក អប់រំដែលបានចាប់ផ្តើមតាំងពីឆ្នាំ 1901 មកម្ល៉េះ ការបណ្តុះបណ្តាលសិស្សស្រីឱ្យក្លាយជាបុគ្គលដែលមានគោលដៅច្បាស់លាស់ ថែមទាំងទទួលបានការលើកទឹកចិត្តការផ្តល់សិទ្ធតាមរយៈបទពិសោធន៍នៃការបង្រៀន និងការសិក្សាដែលមានគុណភាពខ្ពស់បំផុត។ ស្ថិតនៅក្នុងទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ក្នុងតំបន់ Upper North Shore ដែលមានទេសភាពស្រស់ស្អាត និងសម្បូរទៅដោយដើមឈើបៃតង សិស្សនារីរបស់យើងទទួលបាននូវបរិយាកាសសិក្សាដ៏ស្រស់ត្រកាល និងបរិក្ខារលំដាប់ពិភពលោកដែលទទួលបានពានរង្វាន់ជាច្រើន។

Ravenswood គឺជាសាលាដែលទទួលបានពានរង្វាន់ច្រើនលើផ្នែក «ការអប់រំផ្អែកលើភាពវិជ្ជមាន» (Positive Education) និង «សុខុមាលភាព» (Visible Wellbeing) ហើយផ្តល់ជូនសិស្សនូវសកម្មភាពក្រៅកម្មវិធីសិក្សាច្រើនជាង 100 ប្រភេទ។ លើសពីនេះ Ravenswood ក៏ផ្តល់ជូនសិស្សថ្នាក់ចុងក្រោយនូវជម្រើសរវាងកម្មវិធី HSC និងកម្មវិធី International Baccalaureate Diploma ផងដែរ។

# St Aidan's Anglican Girls' School





| ព័ត៌មានអំពីសាលា | |
|---|---|
| ក្រុង/ រដ្ឋ | QLD |
| ឆ្នាំបង្កើត | 1929 |
| ប្រភេទសាលា | ស្រី |
| ការស្នាក់នៅ | អាគារស្នាក់នៅ នៅជាមួយគ្រួសារ |
| កម្មវិធី ELICOS | គ្មាន |
| កម្មវិធីភាសាអង់គ្លេសផ្សេងទៀត | មាន |
| វិញ្ញាបនបត្របញ្ចប់ការសិក្សា | QCE |
| ចំនួនសិស្សចុះឈ្មោះចូលរៀនសរុប | 1200 |
| ចំនួនសិស្សអន្តរជាតិសរុបបច្ចុប្បន្ន (500 ទិដ្ឋាការ) | 61 |
| តម្រូវការតេស្ត AEAS | តម្រូវការ |
| ថ្លៃសិក្សា | AUD $42,648-$49,644 |
| ថ្លៃកន្លែងស្នាក់នៅ | AUD $18,800 |
| លេខ CRICOS | 01194K |

**Booth Number 4**

សាលា St Aidan’s Anglican Girls’ School គឺជាសាលាឯកជនឈានមុខមួយសម្រាប់សិស្សស្រី ចាប់ពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ទី 12 ដែលមានទីតាំងនៅទីក្រុង Brisbane រដ្ឋ Queensland ប្រទេសអូស្ត្រាលី។ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1929 សាលានេះផ្តល់ការអប់រំប្រកបដោយគុណភាព ក្នុងបរិយាកាសគាំទ្រ និងផ្អែកលើគុណតម្លៃ ដែលជួយឱ្យសិស្សានុសិស្សអភិវឌ្ឍសក្តានុពលរបស់ខ្លួនឱ្យបានពេញលេញ។

សាលាត្រូវបានទទួលស្គាល់ដោយសារលទ្ធផលសិក្សាខ្ពស់ ការថែទាំសុខុមាលភាពសិស្សដ៏ល្អប្រសើរ និងឱកាសជ្រើសរើសច្រើនបែបក្នុងវិស័យកីឡា តន្ត្រី សិល្បៈ វប្បធម៌ ភាពជាអ្នកដឹកនាំ និងសេវាកម្មសហគមន៍។
សិស្សអន្តរជាតិទទួលបានការគាំទ្រយ៉ាងយកចិត្តទុកដាក់ រួមមានការថែទាំផ្នែកសុខុមាលភាព ជំនួយភាសាអង់គ្លេស និងការណែនាំផ្នែកសិក្សាជាលក្ខណៈបុគ្គល។ សិស្សបញ្ចប់ការសិក្សាពីសាលា St Aidan’s ជាច្រើនបានបន្តការសិក្សានៅសាកលវិទ្យាល័យល្បីៗទាំងក្នុង និងក្រៅប្រទេស។ សាលាផ្តល់បរិយាកាសសុវត្ថិភាព កក់ក្តៅ និងរួមបញ្ចូល ដែលជួយឱ្យសិស្សអភិវឌ្ឍជំនាញ ទំនុកចិត្ត និងចរិតលក្ខណៈសម្រាប់ភាពជោគជ័យក្នុងពិភពលោកនាពេលអនាគត។

# St Leonard's College





## ព័ត៌មានអំពីសាលា

| | |
|---|---|
| ក្រុង/ រដ្ឋ | VIC |
| ឆ្នាំបង្កើត | 1914 |
| ប្រភេទសាលា | ការសិក្សារួមថ្នាក់ |
| ការស្នាក់នៅ | នៅជាមួយគ្រួសារ |
| កម្មវិធី ELICOS | មាន |
| កម្មវិធីភាសាអង់គ្លេសផ្សេងទៀត | មាន |
| វិញ្ញាបនបត្របញ្ជាក់ការសិក្សា | VCE/IBDP |
| ចំនួនសិស្សចុះឈ្មោះចូលរៀនសរុប | 1666 |
| ចំនួនសិស្សអន្តរជាតិសរុបបច្ចុប្បន្ន (500 ទិដ្ឋាការ) | 60 |
| តម្រូវការតេស្ត AEAS | តម្រូវការ |
| ថ្លៃសិក្សា | AUD $36,891-$59,415 |
| ថ្លៃកន្លែងស្នាក់នៅ | មិនអាចអនុវត្តបានទេ |
| លេខ CRICOS | 00343K |

**Booth Number 5**

សាលា St Leonard's គឺជាសាលាឯកជនសិក្សាឈានមុខគេមួយនៅទីក្រុងម៉េលប៊ិន ដែលផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ ចាប់ពីកម្រិតអប់រំកុមារតូច រហូតដល់ថ្នាក់ទី12។

សាលាមានទីតាំងនៅ Brighton ក្នុងតំបន់ Bayside ដ៏មានកិត្យានុភាពរបស់ទីក្រុងមែលប៊ិន។ មហាវិទ្យាល័យផ្តល់បរិយាកាសសិក្សាដែលមានភាពកក់ក្តៅ គាំទ្រ និងមានស្តង់ដារខ្ពស់ ដើម្បីលើកទឹកចិត្តសិស្សឱ្យសម្រេចបានសក្តានុពលខ្ពស់បំផុតរបស់ខ្លួន អភិវឌ្ឍភាពជឿជាក់ និងត្រៀមខ្លួនសម្រាប់ការសិក្សានៅសាកលវិទ្យាល័យ និងជីវិតនាពេលអនាគត។

សាលាត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយចំពោះលទ្ធផលសិក្សាដ៏លេចធ្លោ។ សិស្សជំនាន់ឆ្នាំ 2025 របស់យើង សម្រេចបានពិន្ទុ ATAR មធ្យមសម្រាប់កម្មវិធី IBDP ចំនួន 95.5 ដែលស្មើនឹងពិន្ទុ IBDP មធ្យម 39.5។ សិស្សដែលបញ្ចប់ការសិក្សារបស់យើងបន្តចូលរៀននៅសាកលវិទ្យាល័យឈានមុខគេក្នុងប្រទេសអូស្ត្រាលី និងនៅទូទាំងពិភពលោក រួមមាន Harvard, Oxford និង Cambridge។

នៅកម្រិតមធ្យមសិក្សាទុតិយភូមិ សិស្សអាចជ្រើសរើសរវាងកម្មវិធី Victorian Certificate of Education (VCE) និងកម្មវិធីសញ្ញាបត្របាក់ឌុបអន្តរជាតិ International Baccalaureate Diploma Programme (IBDP) ដែលផ្តល់ផ្លូវសិក្សាបត់បែន និងទូលំទូលាយទៅកាន់សាកលវិទ្យាល័យនានាទូទាំងពិភពលោក។

សិស្សអន្តរជាតិទទួលបានការគាំទ្រផ្ទាល់ខ្លួនលើការអភិវឌ្ឍភាសាអង់គ្លេស ការសិក្សា សុខុមាលភាព និងការត្រៀមខ្លួនសម្រាប់សាកលវិទ្យាល័យ។ សិស្សដែលត្រូវការពង្រឹងសមត្ថភាពភាសាអង់គ្លេស អាចចូលរៀនតាមរយៈកម្មវិធីភាសាអង់គ្លេសពង្រឹងរបស់យើង មុននឹងផ្លាស់ប្តូរទៅថ្នាក់សិក្សាទូទៅ។

ក្រៅពីឧត្តមភាពផ្នែកសិក្សា សិស្សក៏មានឱកាសចូលរួមយ៉ាងទូលំទូលាយក្នុងវិស័យកីឡា តន្ត្រី សិល្បៈសម្តែង ភាពជាអ្នកដឹកនាំ និងការអប់រំក្រៅថ្នាក់។

នៅសាលា St Leonard's សិស្សគ្រប់រូបត្រូវបានស្គាល់ យល់ដឹង គាំទ្រ និងរៀបចំយ៉ាងល្អ ដើម្បីឈានទៅរកភាពជោគជ័យនាពេលអនាគត។

# Toorak College





| ព័ត៌មានអំពីសាលា | |
|---|---|
| ក្រុង/ រដ្ឋ | VIC |
| ឆ្នាំបង្កើត | 1874 |
| ប្រភេទសាលា | ស្រី |
| ការស្នាក់នៅ | ផ្ទះស្នាក់នៅជាមួយគ្រួសារ |
| កម្មវិធី ELICOS | គ្មាន |
| កម្មវិធីភាសាអង់គ្លេសផ្សេងទៀត | មាន |
| វិញ្ញាបនបត្របញ្ចប់ការសិក្សា | VCE |
| ចំនួនសិស្សចុះឈ្មោះចូលរៀនសរុប | 1004 |
| ចំនួនសិស្សអន្តរជាតិសរុបបច្ចុប្បន្ន (500 ទិដ្ឋាការ) | 69 |
| តម្រូវការតេស្ត AEAS | តម្រូវការ |
| ថ្លៃសិក្សា | ថ្នាក់ទី5– ទី12<br>AUD $44,018-$51,392 |
| ថ្លៃកន្លែងស្នាក់នៅ | AUD $42,012 |
| លេខ CRICOS | 00349D |

**Booth Number 6**

សាលា Toorak College គឺជាសាលាសម្រាប់សិស្សស្រីដែលផ្តោតលើការអភិវឌ្ឍសិស្សឱ្យមានទំនុកចិត្ត សមត្ថភាព និងហ៊ានស្វែងយល់អ្វីថ្មីៗ។ សាលាបានបង្កើតឡើងជាង 150 ឆ្នាំ មកហើយ ដោយរួមបញ្ចូលទាំងប្រពៃណី និងការអប់រំបែបទំនើប។ សាលាស្ថិតនៅលើទីធ្លាបរិវេណធំទូលាយ 11.5 ហិកតា នៅ Mornington Peninsula ដែលមានអគារ និងបរិក្ខារទំនើប បរិយាកាសសិក្សាល្អ សួនច្បារស្រស់ស្អាត និងទេសភាពដ៏ស្រស់បំព្រងនៃ Port Phillip Bay។

ចាប់ពីថ្នាក់ទី7 ដល់  ទី9 សិស្សនៅសាលា Toorak College រៀនតាមរបៀបដែលជម្រុញការចង់ស្វែងយល់ គំនិតច្នៃប្រឌិត និងជំនាញសម្រាប់អនាគត តាមរយៈការរៀនដែលភ្ជាប់ជាមួយស្ថានភាពពិត។ ចាប់ពីទី 10 ដល់ ទី 12 សិស្សអាចជ្រើសរើសផ្លូវសិក្សាដែលសមស្របនឹងចំណាប់អារម្មណ៍ និងគោលដៅរបស់ខ្លួន ដើម្បីត្រៀមខ្លួនសម្រាប់សាកលវិទ្យាល័យ និងអាជីពនាពេលអនាគត។ តាមរយៈកម្មវិធីតភ្ជាប់ការសិក្សា និងឱកាសអនាគត (Pathways and Partnerships Program) សិស្សទទួលបានឱកាសស្វែងយល់ពីវិស័យការងារ ទទួលការណែនាំពីអ្នកជំនាញ និងអភិវឌ្ឍជំនាញដែលមានប្រយោជន៍សម្រាប់អនាគត។

ផ្ទះស្នាក់នៅក្នុងសាលា (Boarding House) ទទួលស្វាគមន៍សិស្សមកពីប្រទេសអូស្ត្រាលី និងជុំវិញពិភពលោក។ នៅទីនេះ សិស្សរស់នៅក្នុងសហគមន៍ដែលមានភាពចម្រុះ ការគាំទ្រ និងការយកចិត្តទុកដាក់។ សាលាលើកទឹកចិត្តឱ្យសិស្សស្រីគ្រប់រូបមានទំនុកចិត្តក្នុងការស្រមៃពីគោលដៅធំៗ ខិតខំសម្រេចលទ្ធផលសិក្សាល្អ និងក្លាយជាមនុស្សដែលអាចចូលរួមបង្កើតភាពវិជ្ជមានដល់សង្គម និងពិភពលោក។

# Wesley College





| ព័ត៌មានអំពីសាលា | |
|---|---|
| ក្រុង/ រដ្ឋ | VIC |
| ឆ្នាំបង្កើត | 1866 |
| ប្រភេទសាលា | ការសិក្សារួមថ្នាក់ |
| ការស្នាក់នៅ | ផ្ទះស្នាក់<br>អាគារស្នាក់នៅ<br>នៅជាមួយគ្រួសារ |
| កម្មវិធី ELICOS | មាន |
| កម្មវិធីភាសាអង់គ្លេសផ្សេងទៀត | មាន |
| វិញ្ញាបនបត្របញ្ចប់ការសិក្សា | VCE/IBDP |
| ចំនួនសិស្សចុះឈ្មោះចូលរៀនសរុប | 3400 |
| ចំនួនសិស្សអន្តរជាតិសរុបបច្ចុប្បន្ន (500 ទិដ្ឋាការ) | 92 |
| តម្រូវការតេស្ត AEAS | តម្រូវការ |
| ថ្លៃសិក្សា | ថ្នាក់ទី5– ទី12<br>AUD $48,541-$55,974 |
| ថ្លៃកន្លែងស្នាក់នៅ | ថ្នាក់ទី7– ទី12 AUD $35,000 |
| លេខ CRICOS | 00354G |
| **Booth Number 7** | |

សាលា Wesley College គឺជាសាលាឯកជនសម្រាប់សិស្សប្រុស និងស្រី ដែលមានបទពិសោធន៍ក្នុងការអប់រំជាង 160 ឆ្នាំ និងទទួលស្គាល់ជាសាលា IB World School។ សាលាមានជម្រើសទាំង ការសិក្សាធម្មតា (Day School) និងការស្នាក់នៅក្នុងសាលា (Boarding School) នៅតាមសាខាទាំង 3 ក្នុងទីក្រុងមែលប៊ន  (Melbourne)។ សាលា Wesley College មិនត្រឹមតែផ្តោតលើការសិក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យសិស្សអភិវឌ្ឍជំនាញ ស្វែងរកទេពកោសល្យ និងបង្កើនទំនុកចិត្ត ដើម្បីត្រៀមខ្លួនសម្រាប់អនាគត។

សាលា Wesley College មានកេរ្តិ៍ឈ្មោះល្បីល្បាញផ្នែកលទ្ធផលសិក្សាដ៏ឆ្នើម។ សិស្សអាចជ្រើសរើសសិក្សាកម្មវិធី Victorian Certificate of Education (VCE) ឬ International Baccalaureate Diploma Programme (IB DP)។ សិស្សដែលបានបញ្ចប់ការសិក្សាពីសាលា Wesley College ជាច្រើនបានបន្តការសិក្សានៅសាកលវិទ្យាល័យល្បីៗក្នុងប្រទេសអូស្ត្រាលី និងជុំវិញពិភពលោក រួមមាន សាកលវិទ្យាល័យ Cambridge, Pennsylvania State University និង University of Texas។

សាលា Wesley College ក៏មានកម្មវិធីសិក្សា ត្រៀមភាសាអង់គ្លេស (ELPP) ដើម្បីជួយសិស្សអន្តរជាតិពង្រឹងជំនាញភាសាអង់គ្លេស និងត្រៀមខ្លួនចូលរៀនក្នុងថ្នាក់ធម្មតាបានយ៉ាងមានទំនុកចិត្ត។ សម្រាប់សិស្សថ្នាក់ទី7 ដល់ ទី12 សាលាផ្តល់ជម្រើស កន្លែងស្នាក់នៅទំនើប សុវត្ថិភាព និងផាសុកភាព។ សាលាទទួលសិស្សស្នាក់នៅមកពីប្រទេសអូស្ត្រាលី និងប្រទេសផ្សេងៗជុំវិញពិភពលោក។

បាន បង្កើត ឡើងដោយ

AEAS

# ទិន្នន័យព័ត៌មាន សាលានៅអូស្ត្រាលី



ជាង ៥០ សាលា

## ស្វែងរក និងប្រៀបធៀប
## ស្វែងរកកន្លែងដែលទំនេរ

**australianschools.aeas.com.au**

40 YEARS OF QUALITY INTERNATIONAL STUDENT ASSESSMENTS

AEAS®

40 YEARS OF QUALITY INTERNATIONAL STUDENT ASSESSMENTS

# វគ្គសិក្សាបម្រុងរបស់ AEAS

## ទំនាក់ទំនងដៃគូផ្តល់វគ្គសិក្សាផ្លូវការរបស់យើង សម្រាប់ព័ត៌មានបន្ថែមអំពីវគ្គសិក្សាតាមអនឡាញ

AUSTRALIAN INSTITUTE of LANGUAGE

### AUSTRALIAN INSTITUTE OF LANGUAGE

+61 3 9670 8868

admin@ail.vic.edu.au

ail.edu.au

ELITE COLLEGE OF ENGLISH

### ELITE COLLEGE OF ENGLISH

+61 2 8350 6773

hello@ece.nsw.edu.au

ece.nsw.edu.au

- បង្រៀន ដោយ គ្រូ ភាសា អង់គ្លេស ជនជាតិដើម
- ម៉ូឌុល៦/ រយៈវេលា ៤២ម៉ោង
- ត្រៀមសម្រាប់ការសិក្សានៅសាលាមធ្យមសិក្សាភាសាអង់គ្លេស
- ការពង្រីកទំនុកចិត្ត ក្នុងការសន្ទនាជាភាសាអង់គ្លេស
- វិញ្ញាបនប័ត្រនៅពេលបញ្ចប់វគ្គ



វគ្គសិក្សានេះអាចផ្តល់ជូនតាមអនឡាញជុំវិញពិភពលោក!

AEAS®

40 YEARS OF QUALITY INTERNATIONAL STUDENT ASSESSMENTS

# វគ្គសិក្សាតេស្តត្រៀមចូលរៀន AEAS ជាផ្លូវការ



អាន, សរសេរ, និយាយ,ស្តាប់, ពាក្យ

ម៉ូឌុល៥ / រយៈវេលា ៣០ម៉ោង

វគ្គសិក្សាសម្រាប់ត្រៀមប្រឡង

ជួយភាសាអង់គ្លេសឲ្យមានការ
រីកចម្រើនច្បាស់លាស់

អនុវត្តសម្រាប់ការធ្វើតេស្ត AEAS

វគ្គសិក្សានេះអាចផ្តល់ជូន
តាមអនឡាញជុំវិញ
ពិភពលោក!

## ស្វែងយល់បន្ថែមអំពី
## AEAS Preparation Courses

AIL
Ostium ad futura in vobis
AUSTRALIAN INSTITUTE of LANGUAGE

**AUSTRALIAN INSTITUTE OF LANGUAGE**

+61 3 9670 8868

admin@ail.vic.edu.au

ail.edu.au

ELITE COLLEGE OF ENGLISH

**ELITE COLLEGE OF ENGLISH**

+61 2 8350 6773

hello@ece.nsw.edu.au

ece.nsw.edu.au

aeas.com.au/preparation-courses

SPRINGBOARD Education Cambodia

#6, Street 574, Beoung Kak II,
Toul Kork, Phnom Penh

85515 961 861

central@springboard4education.com

springboard4education.com

@springboard4education015




SpringBoard4Education ប្រចាំនៅកម្ពុជា ផ្តល់សេវាកម្មអប់រំដែលល្អបំផុត និងមានការប្តេជ្ញាចិត្តដ៏មោះមុតក្នុងការយកចិត្តទុកដាក់ចំពោះអតិថិជនគ្រប់រូបដែលប្រើសេវាកម្មជាមួយពួកយើង ។ សេវាកម្មចម្បងរបស់យើងមានដូចជា ៖

- ការបញ្ជូនសិស្សានុសិស្ស បន្តការសិក្សានៅបរទេសជាមួយស្ថាប័នអប់រំគុណភាពអន្តរជាតិ (ប្រទេសអូស្ត្រាលី ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក នូវែលសេឡង់ កាណាដា សិង្ហបុរី និងបណ្តាលប្រទេសផ្សេងទៀត)
- ការប្រឡងភាសាអង់គ្លេសអន្តរជាតិ
- CAMPUS UK - មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាអង់គ្លេស
- វិទ្យាស្ថានស្ព្រីងបត ៖ ដើរតួជាសាកលវិទ្យាល័យក្នុងស្រុក ដែរមានសហការជាមួយសាកលវិទ្យាល័យក្រៅប្រទេស ក្នុងការផ្តល់កម្មវិធីសិក្សាអន្តរជាតិ ថ្នាក់បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់

ក្រុមការងាររបស់យើងសុទ្ធសឹងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬ វិញ្ញាបនបត្រពីចក្រភពអង់គ្លេស សហរដ្ឋអាមេរិក នូវែលសេឡង់ និងអូស្ត្រាលី ហើយពួកយើងមានការបណ្តុះបណ្តាល និង ត្រូវបានទទួលស្គាល់ពីក្រុមប្រឹក្សារបស់ចក្រភពអង់គ្លេស (British Council) ។

WEduAbroad
Study Abroad Consultancy




Street Diamond Island, 38th Floor, Unit G38, GIA Tower, Sopheak Mongkol Rd, Phnom Penh

023 902 903 | 017 54 83 54
081 63 63 60

info@weduabroad.com

weduabroad.com

@WEduAbroad

គឺជាក្រុមហ៊ុនឈានមុខគេក្នុងសេវាកម្មជ្រើសរើសនិស្សិតអន្តរជាតិទៅសិក្សានៅបរទេស។ យើងជា ភ្នាក់ងារអប់រំដែលមានការអនុញ្ញាត និងជាស្ថាប័នជាផ្លូវការ ទទួលស្គាល់ពីសាកលវិទ្យាល័យល្បីៗ ជាច្រើននៅទូទាំងពិភពលោក។
យើងប្តេជ្ញាផ្តល់ជូនសិស្សនូវការអប់រំដែលមានគុណភាពខ្ពស់នៅទូទាំងពិភពលោក ជាមួយនឹងសេវាកម្ម ប្រឹក្សាដោយឥតគិតថ្លៃរបស់យើង។ សិស្សានុសិស្សត្រូវបានទទួលបានព័ត៌មានទាំងអស់ដែលពួកគេត្រូវការដើម្បីជ្រើសរើសប្រទេសក្នុងក្តីស្រមៃ មុខជំនាញសិក្សា អ្នកផ្តល់សេវាអប់រំ ផ្សារភ្ជាប់ជាមួយនឹងសេដ្ឋកិច្ចរបស់គ្រួសារពួកគេ។
WEduAbroad គឺជាផ្នែកមួយរបស់ WEduShare ដែលជាមាតិកាអប់រំអនឡាញដ៏ធំបំផុតរបស់ ប្រទេសកម្ពុជាដែលផ្តល់ដល់យុវជនកម្ពុជាជាង 100,000 នាក់។

**សេវាកម្មរបស់ WEduAbroad**

1. ការសិក្សានៅក្រៅប្រទេស
    - មានជាង ១០០០ សាកលវិទ្យាល័យ មហាវិទ្យាល័យ និងសាលារៀន
    - ថ្នាក់ត្រៀម បរិញ្ញាបត្រ អនុបណ្ឌិត និងបណ្ឌិត
    - កម្រិត វិទ្យាល័យ បរិញ្ញាបត្រ អនុបណ្ឌិត
    - វគ្គខ្លី និងទស្សនកិច្ចសិក្សា
    - ថ្នាក់ភាសា
2. ការធ្វើវីសា
    - ក្រុមការងាររបស់យើង នឹងជួយអ្នកគ្រប់ជំហានក្នុងការធ្វើវីសា
    - ប្រភេទវីសាសិស្ស ទេសចរណ៍ និងអាណាព្យាបាលសិស្សសម្រាប់ ស្នាក់នៅយូរអង្វែង ភាពជោគជ័យរបស់យើងគឺច្រើនជាង ៩០%
3. សំបុត្រយន្តហោះ
    - លោក លោកស្រីមិនចាំបាច់ពិបាក រឿងសំបុត្រយន្តហោះនោះទេ ពួកយើងមានសេវាកម្មកក់សំបុត្រយន្តហោះក្នុងតម្លៃសមរម្យ

AEAS®

# ត្រៀមខ្លួនសម្រាប់ភាពជោគជ័យ...

## ជាមួយនឹងការធ្វើតេស្តអនុវត្តផ្លូវការរបស់ AEAS!




### សៀវភៅតេស្តអនុវត្ត

### ការធ្វើតេស្តអនុវត្តតាមអនឡាញ

គ្រប់ពេលវេលា គ្រប់ទីកន្លែង



Scan the QR code

ស្វែងយល់បន្ថែមអំពីជម្រើសដ៏ល្អទាំងពីរនេះនៅលើគេហទំព័ររបស់យើង

*aeas.com.au/practice-tests*




AEAS
aeas.com.au






AEAS














AEAS®

aeas.com.au

+61 3 9645 0077

admin@aeas.com.au

AEASCambodia